អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៧

# សេចក្ដីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះសាលាដំបូងបញ្ចប់សវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២, កំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ និងសេចក្ដីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល

នៅថ្ងៃពុធ ទី ១១ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានបិទបញ្ចប់សវនាការលើភ័ស្តុតាង នៅក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងបទចោទប្រកាន់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។

អង្គជំនុំជម្រះបានចាប់ផ្ដើមសវនាការលើភ័ស្តុតាង នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ និង បានស្ដាប់ការបង្ហាញភ័ស្តុតាងលើប្រធានបទស្តីពីសហករណ៍ត្រាំកក់ (រួមទាំង មន្ទីរសន្តិសុខក្រាំងតាចាន់ និង ការប្រព្រឹត្តិលើពុទ្ធសាសនិក) ការដ្ឋានទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម ការប្រព្រឹត្តិលើជនជាតិចាម និង វៀតណាម មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល និង មន្ទីរសន្តិសុខ ស-២១ និងការបោសសំអាតផ្ទៃក្នុង ការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និង ជាចុងក្រោយ តួនាទីរបស់ជនជាប់ចោទ។

អង្គជំនុំជម្រះបានធ្វើសវនាការរយៈពេល ២៧៤ ថ្ងៃ នៅក្នុងសំណុំរឿង ០០២/០២ និងបានស្ដាប់សក្ខីកម្មសាក្សីចំនួន ១១៤ នាក់ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ និងអ្នកជំនាញចំនួន ៨ នាក់។ លើសពីនេះទៀត អង្គជំនុំជម្រះបានផ្ដល់ឱកាសឲ្យភាគីបង្ហាញភ័ស្តុតាងជាឯកសារសំខាន់ៗ ពាក់ព័ន្ធនឹងប្រធានបទសវនាការនីមួយៗ និង បានស្ដាប់ការបញ្ជាក់បឋមរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្តីពីការទាមទារសំណង។ នៅក្នុងអំឡុងពេលសវនាការសំណុំរឿង០០២/០២ នេះ មានសាធារណជនសរុបចំនួន ៧៧ ៦០៤ នាក់ បានចូលរួមស្ដាប់ដោយផ្ទាល់នៅក្នុងសាលសវនាការរបស់ អ.វ.ត.ក។

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧។ កាលបរិច្ឆេទសម្រាប់បណ្តឹងទាមទារសំណងចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៧។ សេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងចាប់ផ្ដើមនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧ ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេល ០១ ថ្ងៃ ដើម្បីបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួន។ សហព្រះរាជអាជ្ញាមានរយៈពេល ០៣ ថ្ងៃ ហើយមេធាវីការពារក្តីក្រុមនីមួយៗមានរយៈពេល ០២ ថ្ងៃ ដើម្បីបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួន។ អង្គជំនុំជម្រះបានកំណត់រយៈពេល ០១ ថ្ងៃ សម្រាប់ការរៀបចំការធ្វើសេចក្តីសន្និដ្ឋានតប និងបានកំណត់រយៈពេល ០៤ ម៉ោង សម្រាប់ការធ្វើសេចក្តីថ្លែងចុងក្រោយរបស់ជនជាប់ចោទផងដែរ ប្រសិនបើជនជាប់ចោទជ្រើសរើសអនុវត្តសិទ្ធិនេះ។

សំណុំរឿង ០០២/០១ ប្រឆាំងនឹងជនជាប់ចោទដដែលនេះ ដែលរួមមានបទចោទអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ការផ្លាស់ទីលំនៅប្រជាជនផ្សេងៗទៀត និងការសម្លាប់នៅទួលពោធិ៍ជ្រៃ បានបញ្ចប់ដោយមានការចេញសាលដីកាស្ថាពរ កាលពីខែ វិច្ឆិកា ឆ្នាំ ២០១៦ កន្លងមក។

អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចផងដែរ ចំពោះអង្គហេតុ និង បទចោទនានាដែលនៅសេសសល់ នៅក្នុងសំណុំរឿង ០០២ នាពេលឆាប់ៗខាងមុខនេះ។

អង្គជំនុំជម្រះសាលាដំបូង បានប្រកាសផ្អាកសវនាការរហូតដល់ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧ ដែលជាកាលបរិច្ឆេទសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះនឹងចេញសាលក្រមក្នុងសំណុំរឿង ០០២/០២ នៅក្នុងរយៈពេលសមស្របខាងមុខ។

*ចំពោះព័ត៌មានបន្ថែមទៀត សូមទាក់ទង៖*

**លោកស្រី ហាយ៉ាត់ អាប៊ូ-សាឡេស**
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ៩៣៦
ទូរស័ព្ទលើតុ: +៨៥៥ (០) ២៣ ៨៦០ ១៩១
សារអេឡិចត្រូនិក៖ abusaleh@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ: +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh